# ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចទីក្រុង ៖ សម្របសម្រួលដល់ការបង្កើតទម្រង់ និង ជំហាន

## តើអ្វីទៅជាការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋ?

ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋ គឺជាការសំខាន់សម្រាប់ពង្រឹងការផ្តល់អំណាចដល់ប្រជាពលរដ្ឋ។ ថ្មីៗនេះ មានការផ្តោតជាសំខាន់លើសក្តានុពលនៃសកម្មភាពប្រមូលផ្តុំ និង ការស្ម័គ្រចិត្តគ្រប់ប្រភេទទាំងអស់ដោយប្រជាពលរដ្ឋ ។ វាហាក់បី ដូចជាដំណើរការមួយដែលទទួលស្គាល់ប្រជាពលរដ្ឋ ឬ តំណាងរបស់ពួកគេ ដើម្បីឱ្យមានឥទ្ធិពល ឱ្យបែងចែកនិងឱ្យត្រួតពិនិត្យកិច្ចការសាធារណៈ ។ ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋមិនត្រឹមតែជាព្រឹត្តិការណ៍កើតឡើងជាប់គ្នាប៉ុណ្ណោះទេ ក៏ប៉ុន្តែជាដំណើរការដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋក្នុងដំណើរការសេដ្ឋកិច្ច សង្គម វប្បធម៌ និង នយោបាយ ដែលដំណើរការទាំងនោះមានឥទ្ធិពលដល់ការរស់នៅរបស់ពួកគេផងដែរ (UNDP HDR 1993)។ ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋ ត្រូវគេស្គាល់ផងដែរទៅលើការចងភ្ជាប់គ្នាបន្តបន្ទាប់នៃមធ្យោបាយ លំហូរព័ត៌មានមួយ ទៅដល់សាធារណជន ទៅកាន់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗគ្នា ជាទម្រង់នៃការប៉ាន់ប្រមាណដោយមានការចូលរួមនិងពិភាក្សា ការសហការដែលរួមបញ្ចូលរួមទាំងការងារ និងចែករំលែកការធ្វើសេចក្តីសម្រេចចិត្តរវាងអ្នកសម្របសម្រួល និងអ្នកពាក់ព័ន្ធនិងការផ្តល់អំណាច ដែលជាអំណាចក្នុងការធ្វើសេចក្តីសំរេចចិត្ត និង ធនធានដែលបញ្ជូនទៅដល់អង្គការពលរដ្ឋនៅក្នុងទម្រង់ក្រុមអ្នកប្រើប្រាស់ (Edgerton et al. 2000) ។

ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋ គឺខុសពីការចូលរួមដោយខ្លួនឯង តាំងពីកិច្ចការនេះបានជាប់ទាក់ទងជាពិសេសជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតឱ្យមានបណ្តាញនៃការផ្សព្វផ្សាយសំឡេងជ តំណាង និង ការទទួលខុសត្រូវ។ គ្មានគ្រោងណាមួយសម្រាប់ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋទេ ដោយសារវាដើរតួនាទីខុសគ្នាទៅតាមបរិបទសង្គមខុសៗដែរ។ មានគំនិតផ្តួចផ្តើមខុសៗគ្នា ដែលកើតចេញពីគោលបំណងផ្សេងៗគ្នាដែរ។ គំនិតផ្តួចផ្តើមមួយចំនួនសម្រាប់ការចូលរួមខ្វាប់ខ្លួនរបស់ប្រជាពលរដ្ឋនៅកម្រិតជាតិនិងអន្តរជាតិ ដោយរួមបញ្ចូលនូវការមើលថែរក្សាពលរដ្ឋដែលរាប់បញ្ចូលទាំងផែនការអភិវឌ្ឍ កិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ការកសាងសមត្ថភាព និង ការបង្កើតយន្តការសម្រាប់ចែករំលែកព័ត៌មានជាដើម ។

# តើហេតុអ្វីបានជាការចូលរួមខ្វាប់ខ្ជួនរបស់ប្រជាពលរដ្ឋមានសារៈសំខាន់?

រដ្ឋាភិបាល សំដៅទៅលើប្រភេទពិសេសនៃស្ថាប័នសាធារណៈមួយ (រដ្ឋ) ដែលផ្ទេរអំណាចជាផ្លូវការ ដើម្បីធ្វើសេចក្តីសម្រេចចិត្ត ក្នុងនាមជាតំណាងឱ្យសហគមន៍ទាំងមូល។ អភិបាលកិច្ចមានន័យថា ជាកិច្ចដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត ហើយរាល់ការសម្រេចចិត្ត ត្រូវបានធ្វើឡើង តាមកិច្ចដំណើរការនេះ។ អភិបាលកិច្ច ប្រមូលផ្តុំការសម្រេចចិត្ត ដែលធ្វើឡើងដោយប្រត្តិបត្តិករផ្សេងៗគ្នា ដែលក្នុងនោះមានរដ្ឋាភិបាលចូលរួមផងដែរ។ ដោយសារ អភិបាលកិច្ចជាដំណើរការនៃការធ្វើការសម្រេចចិត្តនោះ វាមានសារៈសំខាន់ដើម្បីផ្តោតលើប្រត្តិបត្តិករ (ទាំងផ្លូវការ និងមិនផ្លូវការ) ដែលជាប់ទាក់ទិន ហើយរចនាសម្ព័ន្ធដែលបានបង្កើតឡើង សម្រាប់ប្រមូលផ្តុំលើរាល់ការធ្វើការសម្រេចចិត្ត និង ការអនុវត្តសេចក្តីសម្រេចចិត្តនានា ។ ដំណើរការនៃការធ្វើអភិបាលកិច្ច គឺភាគច្រើន អនុលោមទៅតាមលក្ខណៈច្បាប់ នៅពេលដំណើរការនោះ ត្រូវបានផ្អែកលើគោលការណ៍ប្រជាធិបតេយ្យ ដូចជា ពហុនិយម អ្នកតំណាងចូលរួម ការជាប់ទាក់ទិនរបស់ប្រជាពលរដ្ឋក្នុងការធ្វើការសម្រេចចិត្ត តម្លាភាព និង ការទទួលខុសត្រូវជាដើម។ អភិបាលកិច្ចល្អ គឺនិយាយសំដៅ ទៅលើអភិបាលកិច្ចដែលត្រូវបានធ្វើវិមជ្ឈការ និង ផ្តល់ការចូលរួមពីរាល់ប្រជាពលរដ្ឋទាំងអស់ ហើយប្រកបដោយតម្លាភាព និង ការទទួលខុសត្រូវផងដែរ ។

សំឡេងរបស់ក្រុមប្រជាពលរដ្ឋ រួមជាមួយការចូលរួមយ៉ាងសកម្មរបស់ពួកគេ គួរតែត្រូវបានគិតគូរពិចារណា នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយ។ សំឡេងរបស់ប្រជាជនអាចប្រើ តាមរយៈតំណាងដើរតួជាអន្តរការីរបស់ស្ថាប័នប្រជាពលរដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា ប្រជាធិបតេយ្យបែបតំណាងចូលរួម មិនមែនជាមធ្យោបាយចាំបាច់ដែលបង្ហាញពីក្តីបារម្ភរបស់អ្នកងាយរងគ្រោះបំផុតក្នុងសង្គម ដែលគួរតែត្រូវបានដាក់បញ្ចូល ក្នុងការគិតពិចារណា នៃការធ្វើសេចក្តីសម្រេចចិត្តនោះទេ។ ជាញឹកញាប់ណាស់ ក្រុមអ្នកដែលគេមិនអើពើតែងតែ ត្រូវបានគេដកចេញពីកិច្ចដំណើរការនៃការធ្វើផែនការអភិវឌ្ឍ ហេតុដូច្នេះហើយតម្រូវការរបស់អ្នកក្រីក្រ មិនត្រូវបានគេដាក់បញ្ចូលទៅក្នុងការធ្វើផែនការ ហើយការបែងចែកធនធាន មិនបានសម្រេចទៅដល់គោលដៅអភិវឌ្ឍន៍នៃការកាត់បន្ថយភាពក្រីក្រ និងសមភាពសេដ្ឋកិច្ច-សង្គម នោះឡើយ។ នៅក្នុងបរិបទនេះ វាចាំបាច់ត្រូវតែធ្វើការងារដោយដាក់បញ្ចូលទៅក្នុងការធ្វើផែនការតែម្តង។

ការទទួលខុសត្រូវ ជាតម្រូវការចម្បងនៃអភិបាលកិច្ចល្អ ។ មិនត្រឹមតែស្ថាប័នរដ្ឋាភិបាលប៉ុណ្ណោះទេ

ប៉ុន្តែក៏មានផ្នែកឯកជន និង អង្គការសង្គមស៊ីវិលផងដែរ ដែលគួរបង្កើតការទទួលខុសត្រូវចំពោះសាធារណៈជន និង ស្ថាប័នរបស់ខ្លួន ។ តើធនធានដែលបោះបង់ចោល ត្រូវបានគេយកមកប្រើ ហើយថាតើតម្រូវការសង្គម ជាពិសេស បណ្តាផ្នែកដែលងាយរងគ្រោះ ត្រូវបានគេផ្តល់ឱ្យយ៉ាងដូម្តេច ក្នុងការឆ្លើយតបចំពោះប្រជាពលរដ្ឋគ្រប់ៗរូប ។ ការផ្តល់ព័ត៌មាន គឺសំខាន់សម្រាប់ឱ្យស្ថាប័នសាធារណៈមានការទទួលខុសត្រូវ នៅក្នុងអាណត្តិគ្រប់គ្រងរបស់ខ្លួន ។ ព័ត៌មានគួរតែត្រូវផ្តល់ឱ្យក្នុងទម្រង់សាមញ្ញ សម្រាប់ជាការយល់ដឹង និងជួយដល់ការត្រួតពិនិត្យតាមដាន ។ ទោះបីដូចនេះក្តី តាមរយៈបទពិសោធន៍បង្ហាញថា ការផ្តល់ព័ត៌មានគឺ អាចទទួលបានតែចំពោះក្រុមគោលដៅពិត ប្រាកដ តែប៉ុណ្ណោះ ។ ជាលទ្ធផលគឺ នៅទីណាដែលអ្នកទាំងនោះត្រូវការព័ត៌មានចាំបាច់ នឹងទទួលបានផលប្រយោជន៍ ពីព័ត៌មាននោះ កន្លែងដែលមានការគាំទ្រពីស្ថាប័នតិចតួចក្រុមនោះមិនបានទទួលព័ត៌មានឡើយ ។ ការបង្កើត គម្លាតតាមរយៈសកម្មភាពប្រជាពលរដ្ឋ ក្នុងកិច្ចដំណើរការធ្វើផែនការ ការអនុវត្តផែនការ និង ការធ្វើថវិកា អាចធានាបាននូវការរួមបញ្ចូលនៃក្រុមដែលគេមិនអើពើ ការផ្តល់អំណាចដល់ពលរដ្ឋ ដើម្បីចូលរួមតាមមធ្យោបាយពេញលេញមួយ ក្នុងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ការកសាងតម្លាភាព និង ការទទួលខុសត្រូវក្នុងដំណើរការអភិបាលកិច្ច ។

## ការកសាងដោយមានការចូលរួមខ្វាប់ខ្ជួនពីប្រជាពលរដ្ឋ

មានទម្រង់ផ្សេងៗគ្នា នៃការចូលរួមខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ ដែលអាចជ្រើសរើសបាន ដោយផ្អែកលើគោលបំណង និង បរិបទ ។ ទម្រង់ចំនួន ៤ ប្រភេទដែលរួមមានកិច្ចដំណើរការ និង ការជះឥទ្ធិពលរបស់វាត្រូវបានគេលើកយកមកពិភាក្សា :

### (១) ការត្រួតពិនិត្យដោយមានការចូលរួមនៃសេវាមូលដ្ឋាន (បណ្ណរាយការណ៍)

ប្រជាពលរដ្ឋដែលរស់នៅក្នុងទីប្រជុំជន និង ទីក្រុង ពឹងផ្អែកលើអាជ្ញាធរមូលដ្ឋានក្រុង (the urban local body (ULB)) សម្រាប់ការផ្តល់ផាសុខភាពមូលដ្ឋាន ដូចជា ទឹកស្អាត ផ្លូវថ្នល់ អនាម័យ ការប្រមូលសំរាម ភ្លើងបំភ្លឺតាមផ្លូវថ្នល់ជាដើម ។ វាជាការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានក្រុង ដើម្បីផ្តល់សេវាមូលដ្ឋានទាំងនេះដល់ប្រជាពលរដ្ឋ ។ មានអារម្មណ៍ទូទៅមួយនៃការមិនពេញចិត្ត ទៅលើសេវាសង្គមទាំងនេះដែលបានផ្តល់ឱ្យដោយអាជ្ញាធរមូលដ្ឋានក្រុង ។ ជាញឹកញាយណាស់ដែលតំបន់អ្នកក្រីក្រ និង អ្នកក្រីក្រនៅតំបន់ទីក្រុងត្រូវបានគេទុកចោល ដោយមិនបានទទួលសេវាមូលដ្ឋាន ឬ ត្រូវបានគេបង្ខំឱ្យពឹងផ្អែកតែលើសេវាឯកជនដែលមានតម្លៃខ្ពស់ជាងនោះ ។ ដោយសារបទពិសោធន៍ និងទស្សនៈរបស់ប្រជាពលរដ្ឋ មិនត្រូវគេទទួលស្គាល់ឱ្យដាក់

បញ្ចូលក្នុងការធ្វើផែនការ និងការអនុវត្តនៃសេវាមូលដ្ឋានទាំងនោះ ហើយជាញឹកញយ បញ្ហាជាមូលដ្ឋាន ដែលកើតចេញពីទស្សនៈរបស់អ្នកប្រើប្រាស់ មិនត្រូវបានលើកឡើងដោះស្រាយឡើយ ។ បណ្ណរាយការណ៍ត្រូវតែ ប្រើឱ្យច្រើនថែមទៀត សម្រាប់ការចូលរួមខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ ដើម្បីទាមទារសេវាសង្គមនានា ឱ្យកាន់តែប្រសើរឡើង ។ គេអាចយកវាមកប្រើជាឧបករណ៍ដើម្បីបង្កឱ្យស្ថាប័នគ្រប់គ្រងនានាមានការទទួលខុសត្រូវ ។

បណ្ណរាយការណ៍ជាការវាយតម្លៃដោយមានការចូលរួមដែលអ្នកប្រើប្រាស់ ផ្តល់ឱ្យនូវព័តិមានត្រឡប់ ស្តីពីការប្រព្រឹត្តទៅនៃសេវាសាធារណៈ។ បណ្ណរាយការណ៍ឆ្លុះបញ្ចាំងពីបទពិសោធន៍ជាក់ស្តែងរបស់ប្រជជន ទៅលើកម្រិតនៃសេវាមូលដ្ឋានទាំងឡាយ។ បណ្ណរាយការណ៍ មានគោលបំណងបង្ហាញ នូវទស្សនៈស្តីពីស្ថានភាពនៃសេវាសាធារណៈ ដែលកើតចេញពីទស្សនវិស័យរបស់ប្រជាពលរដ្ឋ និងទទួលបានមកវិញ នូវព័តិមានត្រឡប់ ពីប្រជាពលរដ្ឋ ក្នុងល័ក្ខខ័ណ្ឌសាមញ្ញ ដែលបង្ហាញនូវកម្រិត នៃការពេញចិត្ត និង មិនពេញចិត្តរបស់ពួកគេ ។ អ្នកប្រើប្រាស់វាយតម្លៃសេវា ហើយប្រាប់ទៅដល់អ្នកផ្គត់ផ្គង់វិញ នូវលទ្ធភាពទទួលបានភាពគ្រប់គ្រាន់ ភាពសមរម្យ និងលទ្ធភាពដែលអាចចំណាយបាន នៃសេវាសាធារណៈ និង បញ្ហាទាំងឡាយដែលពួកគេកំពុងប្រឈមមុខ ក្នុងការទទួលបាននូវសេវាទាំងនោះ ។ ទង្វើអាច ជួយធ្វើជាប្លង់គំរូដល់ការដោះស្រាយនៅថ្នាក់មូលដ្ឋាន រហូតដល់បញ្ហានៅទីក្រុង ។ ដំណើរការនេះ ក៏រួមបញ្ចូលផងដែរនូវការផ្តួចផ្តើមគំនិតនៃការពិភាក្សា ជាមួយអ្នកផ្គត់ផ្គង់សេវា ក្នុងការស្វែងរកដំណោះស្រាយនៅថ្នាក់មូលដ្ឋាន ដើម្បីធ្វើឱ្យសេវាប្រសើរឡើង ។ ទង្វើទាំងនេះ នាំទៅរកការគ្រប់គ្រងសេវាតាមបែបចូលរួម។ វាអាចបង្កើតជាមូលដ្ឋានគ្រឹះ សម្រាប់កិច្ចអនុវត្ត ក្នុងការធ្វើផែនការកម្រិតទីក្រុង។

ដើម្បីធ្វើបណ្ណរាយការណ៍ ជាមួយប្រជាពលរដ្ឋពាក់ព័ន្ធ ដំណើរការខាងក្រោមបានពង្រាងដូចតទៅ :

*i.* **ការវាយតម្លៃរហ័សតាមសង្កាត់**

- ដើរកាត់គ្រប់តំបន់របស់ទីប្រជុំជន ជួបជាមួយប្រជាពលរដ្ឋ ហើយជជែកពិភាក្សាមិនផ្លូវការ ទាក់ទងទៅនឹងទីប្រជុំជននេះ ហើយសង្កេតមើលលើល័ក្ខខ័ណ្ឌរួមនៃសេវា ក្នុងទីប្រជុំជន ។
- ប្រមូលព័តិមាន ស្តីពីចំនួនប្រជាជន ក្នុងទីក្រុង/ទីប្រជុំជន ចំនួនប្រជាជន និង ចំនួនគ្រួសារ ក្នុង Wardនីមួយៗ សេចក្តីលំអិតស្តីពីអ្នកតំណាងដែលបានជ្រើសរើស នៃ Ward នីមួយៗ ការបង្ហាញផែនទី Wardក្នុងទីប្រជុំជន និងសេចក្តីលម្អិតពីសេវានានា ដែលបានផ្តល់ឱ្យដោយអាជ្ញាធរក្រុង ។
- រៀបចំកិច្ចប្រជុំជាមួយប្រធាន មន្ត្រីនានា និង អ្នកផ្តល់យោបល់ ដើម្បីថ្លែងពីគោលបំណង

សម្រាប់ការធ្វើបណ្ណរាយការណ៍ ។ គោលបំណងនៃកិច្ចការនេះ គឺដើម្បីស្វែងរកព័ត៌មានត្រឡប់របស់ប្រជាពលរដ្ឋ ដើម្បីធ្វើការរៀបចំឡើងវិញ នូវការបែងចែកសេវាសម្រាប់បំពេញតម្រូវការរបស់អ្នកប្រើប្រាស់ និងធ្វើការអនុវត្តការគ្រប់គ្រងដោយមានការចូលរួម ។

- កំណត់អ្នកពាក់ព័ន្ធផ្សេងៗគ្នា នៅទីប្រជុំជន ។ កិច្ចខិតខំប្រឹងប្រែងគួរតែធ្វើឡើងដើម្បីកំណត់អ្នកដែលត្រូវដកចេញ និងត្រូវមើលរំលង ។

### *ii.* ធ្វើការណែនាំរបស់គណៈកម្មការ Ward/ប្រជាពលរដ្ឋ

- រៀបចំសហគមន៍នៅកម្រិតថ្នាក់ Ward ឬ នៅកម្រិតជាក្រុម។ ពីចំណោមសហគមន៍ ត្រូវកំណត់ អ្នកដឹកនាំពលរដ្ឋក្នុងមួយក្រុមពី ៨-១០ នាក់ ដែលជាអ្នកមានឆន្ទៈធ្វើកិច្ចការនេះ។
- ធ្វើកិច្ចប្រជុំកម្រិតថ្នាក់ Ward និងណែនាំពលរដ្ឋឱ្យចេះប្រើបណ្ណរាយការណ៍ ។ កិច្ចខិតខំប្រឹងប្រែងពិសេសមួយ អាចនឹងត្រូវធ្វើឡើងដើម្បីធានា នូវការចូលរួមរបស់ក្រុមជនងាយរងគ្រោះ ជាពិសេស ក្រុមជនក្រីក្រ នៅតាមទីប្រជុំជន ។
- អញ្ជើញតំណាងដែលបានជ្រើសរើស សម្រាប់កិច្ចប្រជុំពិភាក្សាបញ្ហាទាំងនេះ ដើម្បីកសាងជំនឿទុកចិត្តរបស់សហគមន៍ និងសមាជិកដែលបានជ្រើសរើសរួច។
- គោលគំនិតនៃបណ្ណរាយការណ៍ ហើយមូលហេតុសំខាន់ដែលត្រូវធ្វើបណ្ណរាយការណ៍ និងរបៀបដែលអាចប្រើវាជាឧបករណ៍ ដើម្បីកសាងតម្លាភាព និងការទទួលខុសត្រូវ ដែលចាំបាច់ត្រូវពន្យល់ ដដែលៗ ឬសាចុះសាឡើង។

### *iii.* អត្តសញ្ញាណកម្មនៃសេវា

- កំណត់នូវសេវាដែលត្រូវធ្វើការវាយតម្លៃ និងភ្នាក់ងារដែលទទួលខុសត្រូវចំពោះសេវាទាំងនេះ។ ជាញឹកញាយ ភ្នាក់ងារផ្សេងៗ មានការទទួលខុសត្រូវ ក្នុងការបង្កើត ការធ្វើប្រតិបត្តិការ និងការថែទាំលើសេវា ។ អត្តសញ្ញាណកម្មនៃសេវា គួរតែធ្វើឡើង ដោយផ្អែកលើអាទិភាពរបស់អ្នកប្រើប្រាស់ ។ ឧបករណ៍របស់ PRIA អាចប្រើដើម្បីកំណត់ទាំងសេវា ដែលតឹងតែងបំផុត ឬក៏ទាំងសេវា ដែលគេរិះគន់ច្រើនបំផុត។

### *iv.* បង្កើតអាំងឌីកាទ័រ/ប៉ារ៉ាម៉ែត (ជាមួយសហគមន៍)

- នៅពេលដែលសេវាត្រូវបានកំណត់ ដូចជា (ទឹកស្អាត ផ្លូវថ្នល់ ការចោលសំរាម ភ្លើងបំភ្លឺតាមផ្លូវថ្នល់ និងប្រព័ន្ធប្រឡាយទឹក/ទឹកស្អុយ) នៅក្នុងការពិគ្រោះយោបល់ជាមួយក្រុមប្រជាពលរដ្ឋ ត្រូវបង្កើតឡើង អាំងឌីការទ័រ សម្រាប់ធ្វើការវាយតម្លៃ នូវតម្រូវការសេវា

នីមួយៗ ។ ជាឧទាហរណ៍ សម្រាប់ការវាយតម្លៃនៃការផ្គត់ផ្គង់ទឹកស្អាត អាំងឌីការទ័រដែលត្រូវប្រើអាចជាអាំងឌីកាទ័របង្ហាញ ពេលវេលានៃការផ្គត់ផ្គង់ទឹក កាលវិភាគផ្គត់ផ្គង់ទឹក អំឡុងពេលផ្គត់ផ្គង់ទឹក ដោយរួមទាំងការសង្កេតលើបរិមាណ/សម្ពាធ និង គុណភាពទឹកផង ។

- ប្រជាពលរដ្ឋ អាចបង្កើតទម្រង់គំរូសម្រាប់ប្រមូលព័ត៌មាន ស្ដីពីការផ្ដល់សេវានីមួយៗ ដោយពឹងផ្អែកលើអាំងឌីការទ័រ ។
- ធ្វើការពិភាក្សាមិនផ្លូវការលើបញ្ហានៃលទ្ធភាពអាចធ្វើបាន ភាពអាចរកបាន ភាពគ្រប់គ្រាន់ និងកិច្ចខិតខំប្រឹងប្រែង រួមទាំងបញ្ហាផ្សេងៗទៀត ដូចជាបញ្ហាជម្លោះ សមធម៌ ភាពមិនយកចិត្តទុកដាក់ចំពោះស្ត្រី និង អំពើពុករលួយ ។ល។
- សួរនាំប្រជាជន ដើម្បីធ្វើចំណាត់ថ្នាក់នៃហេតុផលនានា ស្ដីពីការមិនពេញចិត្ត នៅក្នុងតម្រូវការសំខាន់ៗរបស់ពួកគេ ។

### v. ធ្វើបណ្ណរបាយការណ៍

- ដើម្បីធ្វើបណ្ណរាយការណ៍ ចូរចែក Ward ទៅតាមទីតាំងភូមិសាស្ត្រ ដោយត្រូវគិតពិចារណាទៅលើចង្កោមប្រជាជន និង ពលរដ្ឋក្រីក្រនៅតាមប្រជុំជនដែលមានស្រាប់ ។ ផែនទីសង្កាត់ជាជំនួយដ៏មានប្រយោជន៍មួយ ។
- ក្នុង Wardនីមួយៗ ត្រូវចូលរួម យ៉ាងហោចណាស់ ១០ ភាគរយនៃគ្រួសារទាំងអស់ ។ ជាឧទាហរណ៍ ក្នុងមួយ Wardមាន ២០០ គ្រួសារ ត្រូវឱ្យមានអ្នកឆ្លើយតបចំនួន ១៨-២០ តំណាងឱ្យស្ត្រី និងផ្អែកអ្នកងាយរងគ្រោះចូលរួម ។ អ្នកឆ្លើយតប គួរតែរួមបញ្ចូលនូវរាល់ចង្កោមអ្នកមានបញ្ហា និង អ្នកពាក់ព័ន្ធទាំងអស់ ។
- ករណីសិក្សាស៊ីជម្រៅ នៃក្រុមគ្រួសារដែលបានជ្រើសរើស ហើយមានបទពិសោធន៍ជាមួយអ្នកផ្ដល់សេវាសាធារណៈ ក្នុងការទទួលបានសេវាសាធារណៈ អាចផ្ដល់ឱ្យកាន់តែច្បាស់ថែមទៀត ។ ករណីសិក្សាទាំងនេះ ជួយផងដែរដល់ការបង្កើតការស្នើសុំ ពីប្រជាពលរដ្ឋក្នុងការដោះស្រាយបញ្ហាមួយចំនួន ។
- ប្រសិនបើ PRA មិនអាចធ្វើទៅបាន ត្រូវប្រើវិធីសាស្ត្រស្រាវជ្រាវជំនួសវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ ជាមួយការបំពេញទម្រង់ កិច្ចប្រជុំខ្លីជាមួយក្រុមគោលដៅ ក្នុងសង្កាត់ និង នៅតាមផ្លូវ អាចជួយកសាងនូវបរិស្ថាន ដល់ការចូលរួមខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ ។

### *vi.* ការវិភាគទិន្នន័យ

- កិច្ចប្រជុំអ្នកសម្របសម្រួលដែលធ្វើបណ្ណរាយការណ៍ ជួយដល់ការបង្កើតជាឯកសារសម្រាប់ ព័ត៌មានបែបគុណភាព និង ករណីសិក្សា ។
- ព័ត៌មានត្រូវការនៅថ្នាក់ Ward ត្រូវវិភាគជាមួយក្រុមប្រជាពលរដ្ឋ ។
- រៀបចំរបាយការណ៍ឱ្យបានទូលំទូលាយ ពីស្ថានភាពទូទៅនៃសេវាមូលដ្ឋាន នៅក្នុងទីប្រជុំជន ។
- ព័ត៌មានសម្រាប់ Wardនីមួយៗ ត្រូវដាក់ក្នុងទម្រង់មួយដែលសាមញ្ញ និងងាយស្រួលអាន ។ ជាឧទាហរណ៍ នៅក្នុងផែនទី Ward នីមួយៗ កម្រិតនៃសេវាអាចរកបាន និងកម្រិតនៃការពេញចិត្ត ទៅលើសេវានីមួយៗ អាចគេបង្ហាញឱ្យឃើញ ។

### *vii.* ចែករំលែកជាមួយអ្នកផ្តល់សេវា និង សហគមន៍

- ចែករំលែកបណ្ណរាយការណ៍គួរត្រូវរៀបចំជាភាសាក្នុងមូលដ្ឋាន នៅពេលកិច្ចប្រជុំកម្រិតថ្នាក់ Ward ។ ការស្នើសុំបន្ថែមផ្សេងទៀត ដែលធ្វើឡើងដោយសហគមន៍ តម្រូវឱ្យដាក់បញ្ចូលផងដែរ ។ ក្នុងករណីខ្លះ ប្រជាពលរដ្ឋមួយចំនួន លើកឡើងពីដំណោះស្រាយនៅថ្នាក់មូលដ្ឋាន ដែលត្រូវតែកត់ត្រាទុកជាឯកសារ ។
- បន្ទាប់មក បណ្ណរាយការណ៍ ត្រូវបានបង្ហាញទៅអាជ្ញាធរក្រុង ដោយក្រុមប្រជាពលរដ្ឋ ។ វាអាចរកបាននៅទីសាធារណៈឯទៀត ដូចជា សាលារៀន ចំណុចជួបជុំសំខាន់ៗ ក្នុងប្រជុំជន ឬ បណ្ណាល័យ ។ល ។ កន្លែងទាំងនេះ ជួយផ្តួចផ្តើមនូវការសន្ទនា រវាងអ្នកប្រើប្រាស់ និងអ្នកផ្តត់ផ្គង់សេវា ដោយផ្អែកលើភស្តុតាង ។ វាជួយដាក់សម្ពាធផងដែរ ដល់អ្នកផ្តល់សេវា ដើម្បីធ្វើឱ្យប្រសើរឡើង នូវការផ្គត់ផ្គង់សេវារបស់ខ្លួន ។

### *viii.* ចំណុចចាប់ផ្តើមសកម្មភាព

- ផ្អែកលើការរកឃើញបង្ហាញថា កិច្ចខិតខំប្រឹងប្រែងធ្វើឡើង ដើម្បីធ្វើផែនការសកម្មភាព ។ ផែនការសកម្មភាពដែលរួមបញ្ចូលទាំងការចែករំលែកការទទួលខុសត្រូវ ជាអ្វីដែលក្រុមប្រជាពលរដ្ឋ នឹងធ្វើ (រួមបញ្ចូលការដាក់សម្ពាធ ទៅលើអាជ្ញាធរក្រុង ដើម្បីធ្វើឱ្យសេវាប្រសើរឡើង) និង អ្វីដែលអាជ្ញាធរក្រុងនឹងធ្វើ និង ការសម្រេចធ្វើជាអាទិភាពទាំងនោះ ។

## អត្ថប្រយោជន៍នៃការធ្វើបណ្ណរាយការណ៍

▪ ព័ត៌មានដែលបានប្រើជាព័ត៌មានត្រឡប់ដោយអ្នកផ្តល់សេវា ជាញឹកញាប់បានឈានទៅរកកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនគុណភាព លទ្ធភាពអាចទទួលបាន និងការទទួលបានសេវាជាមូលដ្ឋាន ។ នៅក្នុងករណីមួយចំនួន អ្នកក្រីក្រនៅតំបន់ទីក្រុងក៏អាចទទួល បានសេវាផងដែរ ។

▪ បណ្តឹងតវ៉ាការណ៍ដែលធ្វើដោយស្ថាប័ន នាំទៅរកគំរូស្តង់ដារ នៃគុណភាពរបស់សេវាសាធារណៈ

▪ តាមរយៈបណ្តឹងតវ៉ាការណ៍ តម្រូវការ និង អាទិភាពនៃក្រុមជនងាយរងគ្រោះ ត្រូវគេលើកទឹកចិត្តឱ្យបញ្ចេញសំឡេង និងផ្តល់នូវវេទិកាស្របច្បាប់ ដើម្បីទាមទារ នូវសេវាប្រកបដោយគុណភាព ។

▪ បណ្តឹងតវ៉ាការណ៍មិនមែនជាសកម្មភាពធ្វើតែមួយពេលនោះទេ ។ កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើង ដើម្បីបង្កើតឡើងនូវដំណើរការ ជួយដល់ការបង្កើតក្រុមប្រជាពលរដ្ឋ និងភ្ជាប់ជាមួយ អាជ្ញាធរក្នុងមូលដ្ឋាន ។ ក្នុងដំណើរការស្របច្បាប់ បង្កើតឡើងសម្រាប់ការចូលរួមខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ ។

## (២) ការធ្វើផែនការតាមបែបប្រជាពលរដ្ឋជាមជ្ឈមណ្ឌល

វិធីសាស្ត្របុរាណ នៃការធ្វើផែនការ មានលក្ខណៈបែបមជ្ឈការ និងភាគច្រើនធ្វើពីថ្នាក់លើមក ។ គេគិតថាជាកិច្ចអនុវត្តបច្ចេកទេស ដែលធ្វើឡើងដោយអ្នកជំនាញៗ ។ ដោយឡែក ការធ្វើផែនការដោយមានការចូលរួមគឺជាការធ្វើផែនការបែបវិមជ្ឈការដែលធ្វើឡើងពីថ្នាក់ក្រោម ហើយត្រូវបានឯកភាពពីភាគីពាក់ព័ន្ធផ្សេងៗគ្នា ។ វាផ្អែកទៅលើកិច្ចសន្ទនា និង ការពិភាក្សា ជាមួយភាគីពាក់ព័ន្ធនានា និង ត្រូវផ្តោតទៅលើការកសាងទស្សនវិស័យសម្រាប់ទីប្រជុំជន/ទីក្រុង ។ វាមានលក្ខណៈបែបប្រជាធិបតេយ្យ និង ខិតខំព្យាយាមធ្វើឱ្យរដ្ឋ និង សង្គមស៊ីវិលកាន់តែខិតជិតគ្នា (ក្នុងការធ្វើផែនការសង្គម) ។ រដ្ឋ ឬអាជ្ញាធរអភិបាលកិច្ចមូលដ្ឋានត្រូវបាន លើកទឹកចិត្តឱ្យដើរតួនាទីជាអ្នកសម្របសម្រួល ។ ការធ្វើផែនការដោយមានការចូលរួម នាំដល់ការគិតពិចារណា អំពីចំណេះដឹង និងក្តីបារម្ភនានានៃតំបន់មូលដ្ឋាននោះ ។ វាបានមើលទៅដល់សហគមន៍ជាអ្នកដើរតួដែលអាចជួយ ពង្រឹងចំណេះដឹងក្នុងការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេ ។

ការធ្វើផែនការដោយមានការចូលរួម នៅក្នុងបរិបទទីក្រុង ត្រូវបានរួមបញ្ចូលគ្នា នូវផែនការពង្រីក

សេដ្ឋកិច្ច និង សង្គម ។ ខណៈដែលផែនទីទីប្រជុំជន និង ផែនទីហេដ្ឋារចនាសម្ព័ន្ធជួយកំណត់ នូវលទ្ធភាពរកបាន ជារូបវ័ន្ត ឬ លើចំនួនជាក់លាក់ ឬ លើលក្ខណៈគីមីសាស្ត្រ នៃការផ្គត់ផ្គង់ទឹក (តាមរយៈការពិភាក្សាជាក្រុម) កិច្ចប្រជុំនៅថ្នាក់ Ward និង ការពិគ្រោះយោបល់នៃភាគីពាក់ព័ន្ធដែលលើកពីបញ្ហាមូលដ្ឋាន ដូចជាកម្រិតស្តង់ដារ អនាម័យនៅទាប ការជួសជុលត្រូវប្រើពេលយូរ ឬ ដែលចងភ្ជាប់ការបាត់បង់មានកម្រិតខ្ពស់ដូចជា ធ្លាយលូទឹក ដែលបញ្ចូលគ្នាជាមួយលូទឹកមេ ភ្លើងបំភ្លឺតាមផ្លូវដាច់ដាដើម ។ល។

**ជំហានមួយចំនួនគេអាចយកមកប្រើជាបន្តបន្ទាប់ មានដូចខាងក្រោម :**

(i) **ការប្រមូលព័ត៌មាន និង ការវាយតម្លៃស្ថានភាព :** ការប្រមូលឯកសារ និងផែនទីសំខាន់ៗ រួមទាំងផែនការអភិវឌ្ឍ ពីផ្នែកវាយតម្លៃ និងផែនការក្រុង គឺជាចំណុចត្រូវចាប់ផ្តើម ។ តាមព័ត៌មានដែលប្រមូលបានមកពីក្រុមខុសៗគ្នា ជាពិសេស ដែលបានពីតម្រូវការរបស់ក្រុមជនងាយរងគ្រោះ ត្រូវតែដាក់បញ្ចូល ។ ការធ្វើផែនទីសម្រាប់ជនងាយរងគ្រោះ នៅទីប្រជុំជនក៏ជាវិធីសាស្ត្រ មួយផងដែរ ។

(ii) **ការចែករំលែកព័ត៌មានជាមួយប្រជាពលរដ្ឋ :** បន្ទាប់ពីទិន្នន័យ និង ព័ត៌មានបានប្រមូលរួចការវិភាគ និង ការបកស្រាយ លើកដំបូងភ្លាមៗ ចាំបាច់ក៏ត្រូវធ្វើឡើងផងដែរ។ ព័ត៌មានចាំបាច់ត្រូវចែករំលែកជាមួយក្រុមប្រជាពលរដ្ឋ ដើម្បីឱ្យពួកគេអាចផ្តល់នូវព័ត៌មានបន្ថែមពីបញ្ហាដែលមាននៅក្នុងទីប្រជុំជន/ទីក្រុង ។

(iii) **ការវាយតម្លៃដោយមានការចូលរួមនៃសេវាមូលដ្ឋាន :** ធ្វើការវាយតម្លៃ ទៅលើគុណភាពនៃសេវាមូលដ្ឋាន ដោយផ្តើមចេញពីទស្សនៈនៃភាគីពាក់ព័ន្ធផ្សេងៗ ទាំងក្រុមសង្គម និងក្រុមមានអាជីពការងារ ។ ធ្វើកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធ និងភ្នាក់ងារទាក់ទិននានា ទៅលើបញ្ហាដែលត្រូវបានកំណត់ ដោយប្រជាពលរដ្ឋ និង ដោយមានហេតុផលច្បាស់លាស់ ។ ឯកសារដែលគ្រប់ជ្រុងជ្រោយ ដែលផ្អែកលើគម្លាតក្នុងការផ្តល់សេវាចាំបាច់ ត្រូវរៀបចំឱ្យបានល្អ និងអាចផ្សព្វផ្សាយដោយទូលំទូលាយបាន ។ ព័ត៌មានពីគម្លាតទាំងនេះត្រូវ ចែករំលែកតាមរយៈកិច្ចប្រជុំថ្នាក់សង្កាត់ ដែលធ្វើឡើងជាមួយប្រជាពលរដ្ឋ ។

(iv) **ការស្ទាបស្ទង់មតិពីហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត :** ប្រសិនបើអាជ្ញាធរក្រុងមានផែនទីលម្អិត ដែលគ្របដណ្តប់លើសេវារូបវ័ន្ត វាអាចប្រើ ដើម្បីយល់ដឹងពីការគ្របដណ្តប់នោះ និងផ្តួចផ្តើមគំនិតដល់កិច្ចដំណើរការនៃការធ្វើផែនការ ។ គេអាចរៀបចំឡើង នូវសេចក្តីព្រាងផែនទី នៃហេដ្ឋារចនា

សម្ព័ន្ធ សម្រាប់គ្រប់សង្កាត់ទាំងអស់ ក្នុងទីក្រុង ប្រសិនបើផែនទីមិនអាចរកបាន ។ បំពង់ផ្គត់ផ្គង់ទឹក បំពង់លូបង្ហូរទឹកស្អុយ ភ្លើងបំភ្លឺផ្លូវ ផ្លូវថ្នល់ជិតៗ ។ល ។ ត្រូវគេកំណត់ និងដាក់បញ្ចូលក្នុងផែនទី ។ ប្រជាពលរដ្ឋ និង បុគ្គលិក-កម្មករសាលាក្រុង អាចគាំទ្រដល់កិច្ចដំណើរការនេះ ។

(v) **ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីចាត់អាទិភាព នូវតម្រូវការរបស់ប្រជាពលរដ្ឋ :** បន្ទាប់ពីផ្ទៀងផ្ទាត់ព័ត៌មាន ដោយផ្អែកលើសេវាមូលដ្ឋាន និងការស្ទាបស្ទង់មតិ ពីហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្តមក កិច្ចប្រជុំថ្នាក់ក្រុងត្រូវគេរៀបចំឡើង ដើម្បីកំណត់បញ្ហាទូទៅដែលកំពុងប្រឈមមុខនៅ គ្រប់ Ward ។ បញ្ហាត្រូវគេចាត់ថ្នាក់ជាអាទិភាព ។ មានមតិយោបល់ខុសៗគ្នាពីបញ្ហាទាំងឡាយ ត្រូវគេលើកឡើងទៅតាមអាទិភាពនៃបញ្ហា ។ ក្រោយមក បញ្ជីអាទិភាពបញ្ហាមួយ ត្រូវរៀបចំ ឡើង ។

(vi) ***ការរៀបចំសេចក្តីព្រាងនៃសំណើសុំសម្រាប់សង្កាត់ :*** សេចក្តីព្រាងនៃសំណើសុំ អាចគេត្រូវរៀប ចំឡើង សម្រាប់សង្កាត់នីមួយៗ ។ ការគាំទ្រអាចគេផ្តល់ឱ្យចេញពីមន្ត្រីអាជ្ញាធរក្រុង ។ សំណើសុំ តម្រូវឱ្យដាក់បញ្ចូលនូវស្ថានភាពថ្មីៗ គម្លាត និងការធ្វើគម្រោង សម្រាប់រយៈពេល ២០ ឆ្នាំ ដោយ គិតពីពេលនេះទៅពេលខាងមុខ ។ កិច្ចការនេះត្រូវធ្វើឡើង សម្រាប់ទាំងផ្នែកផ្គត់ផ្គង់ និង ផ្នែក តម្រូវការ ។ សំណើសុំទាំងនេះ តម្រូវឱ្យមានការផ្ទៀងផ្ទាត់ នៅថ្នាក់ Ward តាមរយៈកិច្ចប្រជុំ ។ ការសរសេរ ដោយសង្ខេបជាភាសាបែបសាមញ្ញ ស្តីពីការធ្វើផែនការដែលបានស្នើសុំ ដោយមានការ ផ្សព្វផ្សាយទៅដល់ភាគីពាក់ព័ន្ធនានា មានសារៈសំខាន់បំផុត ។

(vii) ***ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសម្រាប់ធ្វើការរៀបចំផែនការទីក្រុង :*** សំណើសុំថ្នាក់ សង្កាត់ ត្រូវបូកសរុបគ្នា ដើម្បីធ្វើការរៀបចំសំណើទៅថ្នាក់ក្រុង ។ ការពិគ្រោះយោបល់ថ្នាក់ក្រុង ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងធ្វើឡើង ដើម្បីបង្ហាញនូវផែនការក្រុង ជាទម្រង់ដ៏សាមញ្ញ ដែល តម្រូវឱ្យរៀបចំឡើង ។ អ្នកចូលរួមមកពីក្រុមជនងាយរងគ្រោះត្រូវធានាឱ្យមានផងដែរ ។ ការស្នើ សុំ និង មតិយោបល់ ដែលលើកឡើងនៅពេលធ្វើការពិគ្រោះយោបល់ ក្នុងចំណោមភាគីពាក់ព័ន្ធ គួរតែដាក់បញ្ចូលទៅក្នុងផែនការនេះផងដែរ ។

(viii) ***ការបោះពុម្ពផ្សាយនូវផែនការអភិវឌ្ឍសម្រាប់ប្រជាជន :*** សេចក្តីព្រាងនៃសំណើសុំចុងក្រោយ ត្រូវបញ្ចប់ ។ សំណើសុំរួមបញ្ចូលនូវសេចក្តីលម្អិតនៃបច្ចេកទេសរបស់គម្រោង ដែលត្រូវទទួលយក ដោយផ្អែកលើមូលដ្ឋានអាទិភាព ដូចដែលបានប៉ាន់ប្រមាណតម្លៃសម្រាប់សំណើសុំនីមួយៗ ។ បន្ទាប់ មក សំណើចុងក្រោយ បានរៀបចំជាឯកសារក្នុងទម្រង់សាមញ្ញ និងផ្សព្វផ្សាយ ក្នុងចំណោម

ប្រជាពលរដ្ឋ ស្ថាប័នមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្សេងៗទៀត ។ ព័ត៌មានពីលទ្ធភាពទទួលបានមូលនិធិ សម្រាប់គម្រោង អាចត្រូវបានគេផ្តល់ឱ្យផងដែរ ។

## (៣) បន្ទប់ការិយាល័យគាំទ្រពីប្រជាពលរដ្ឋ (Nagarik Sahog Kendra)

ផ្អែកលើមូលដ្ឋានការងារប្រចាំថ្ងៃ មានការជាប់ទាក់ទងគ្នាតិចតួចណាស់ រវាងប្រជាពលរដ្ឋ និង ប្រព័ន្ធអភិបាលកិច្ចក្រុង ។ ទាំងមន្ត្រី និង តំណាងដែលបានជ្រើសរើស មិនមានយន្តការណាមួយ ដើម្បីចែករំលែកព័ត៌មានជាមួយប្រជាពលរដ្ឋឡើយ ។ ដើម្បីឱ្យមានការចូលរួមដោយខ្ជាប់ខ្ជួន និង*ព័ត៌មានប្រកបដោយប្រសិទ្ធភាពគួរតែផ្តល់ឱ្យតាមរយៈមធ្យោបាយទាំងពីរយ៉ាង* ដែលក្នុងនោះ **មធ្យោបាយទី ១ គឺត្រូវផ្តល់ដោយអ្នកធ្វើគោលនយោបាយទៅប្រជាពលរដ្ឋ** (គោលនយោបាយ និងកម្មវិធី) ដើម្បីឱ្យពួកគេដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និង **មធ្យោបាយទី ២ គួរតែផ្តល់ដោយប្រជាពលរដ្ឋ ទៅដល់អ្នកធ្វើគោលនយោបាយ** ដែលបែបនេះអាចជួយដល់អ្នកធ្វើគោលនយោបាយ បានយល់ដឹងពីលក្ខខណ្ឌនៅមូលដ្ឋាន និងធ្វើការបង្កើតឡើងដោយសមស្រប ។

ដើម្បីសម្រួលដល់ការចែករំលែកព័ត៌មាន បន្ទប់ការិយាល័យគាំទ្រពីប្រជាពលរដ្ឋ (Citizens Support Cell (CSC)) អាចបង្កើតឡើង ដើម្បីសម្រួលដល់ការចែករំលែកព័ត៌មាន ក្នុងចំណោមប្រជាពលរដ្ឋ និងអាជ្ញាធរក្រុង ។ បន្ទប់ការិយាល័យទាំងនេះ ប្រសើរបំផុតគួរតែមានទីតាំង ស្ថិតនៅក្នុងបរិវេណនៃការិយាល័យសាលាក្រុង ។ គោលបំណង នៃការបង្កើតបន្ទប់ការិយាល័យគាំទ្រពីប្រជាពលរដ្ឋនេះ គឺធ្វើឡើងដើម្បី :

### *(i) ការចែករំលែកព័ត៌មាន*

នៅតាមទីប្រជុំជនតូច និងមធ្យម ដែលមិនមានគណៈកម្មការ Ward ហើយដែលអាចធ្វើសកម្មភាពបែបជាវេទិកា ដោយភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋជាមួយអាជ្ញាធរក្រុង ។ បន្ទប់ការិយាល័យដើរតួជាផ្លូវទំនាក់ទំនង /បង្គួច ដែលប្រជាពលរដ្ឋអាចស្វែងរកព័ត៌មានបានជាទៀងទាត់ ។ បន្ទប់ការិយាល័យអាចរៀបចំកិច្ចប្រជុំទៀងទាត់នៅថ្នាក់ Ward និង ថ្នាក់កម្រង ជាពិសេស ក្នុងការតាំងទីលំនៅមិនផ្លូវការ ឱ្យតំណាងដែលបានជ្រើសរើស ចេញពីWardដែលត្រូវធ្វើតំណាង ។ កិច្ចការនេះផ្តល់ជាឱកាសដល់ក្រុមងាយរងគ្រោះ បញ្ចេញសំឡេងអំពីក្តីបារម្ភ និង បញ្ហារបស់ខ្លួន

មុនពេលតំណាងរបស់ពួកគេ ដែលបានជ្រើសរើស លើកយកបញ្ហាទាំងនេះ ទៅធ្វើការដោះស្រាយ នៅថ្នាក់ក្រុង ។ កិច្ចខិតខំប្រឹងប្រែងនេះ ជួយកសាងការទទួលខុសត្រូវ ក្នុងដំណើរការអភិវឌ្ឍន៍ ។

***(ii) ការគាំទ្រដល់ស្ត្រី និង ក្រុមអ្នកដែលគេមិនអើពើ***

បន្ទប់ការិយាល័យគាំទ្រប្រជាពលរដ្ឋអាចរកបាន និង ផ្តល់ឱ្យប្រជាពលរដ្ឋ នូវការគាំទ្រចាំបាច់ ដើម្បីសម្រួលដល់ការធ្វើការងាររបស់ពួកគេ ។ តំណាងស្ត្រីគួរទទួលការណែនាំពីតួនាទី និងមុខងារខ្លួន និងដឹងពីកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ ធ្វើដូច្នេះ ពួកគេអាចត្រួតពិនិត្យកិច្ចការទាំងនោះបាន ។ បន្ថែមលើការត្រួតពិនិត្យកម្មវិធី ដែលអាចជួយធ្វើឱ្យប្រសើរឡើង ដល់ការចុះជួបក្រុមគោលដៅ និងការចុះមូលដ្ឋានផងដែរ ។ ក្នុងការបោះឆ្នោតនៅថ្នាក់ក្រុង បន្ទប់ការិយាល័យផ្តល់ការគាំទ្រដល់បេក្ខជនជាស្ត្រី ដើម្បីធ្វើការតែងតាំង ។ វាអាចធ្វើឱ្យអ្នកបោះឆ្នោតដឹង តាមរយៈយុទ្ធនាការ ដើម្បីអប់រំប្រជាពលរដ្ឋ ស្តីពីដំណើរការបោះឆ្នោត និង ផ្តល់ជាព័ត៌មាន ពីបេក្ខជននីមួយៗ ផងដែរ ។

***(iii) ធ្វើការណែនាំប្រជាពលរដ្ឋ និង អ្នកតំណាងដែលបានជ្រើសរើសរួច***

ដើម្បីឱ្យអភិបាលកិច្ចក្រុងមានប្រសិទ្ធភាព អ្នកដឹកនាំប្រជាពលរដ្ឋ និងតំណាងដែលបានជ្រើសរើសរួច ត្រូវទទួលបានការណែនាំ ពីទិដ្ឋភាពផ្សេងៗស្តីពីអភិបាលកិច្ច ពិសេសលើបញ្ហាសមធម៌ ភាពងាយរងគ្រោះ យុត្តិធម៌យេនឌ័រ នៅក្នុងដំណើរការអភិវឌ្ឍន៍ ។ កម្មវិធីបណ្តុះបណ្តាលថ្នាក់ក្រុង អាចរៀបចំ តាមមេរៀន ដូចលើកឡើងខាងក្រោម :

- តួនាទី និង ការទទួលខុសត្រូវរបស់អាជ្ញាធរក្រុង
- ការវាយតម្លៃដោយការចូលរួមនៃសេវាមូលដ្ឋាន ដោយប្រើវិធីសាស្ត្របណ្ណរាយការណ៍
- របៀបធ្វើផែនការអភិវឌ្ឍន៍ដោយមានការចូលរួម
- ការកសាងការទទួលខុសត្រូវ នៅក្នុងប្រព័ន្ធអាជ្ញាធរក្រុង
- ការបង្កើតកញ្ចប់ថវិកាក្រុង និង ការកៀងគរធនធាន
- ការណែនាំដល់ដៃគូឯកជនសាធារណៈចំពោះការអភិវឌ្ឍសេវាជាមូលដ្ឋាន
- ក្រៅពីការផ្សព្វផ្សាយកម្មវិធីវគ្គបណ្តុះបណ្តាល ដំណើរទស្សនកិច្ចសិក្សា អាចនឹងត្រូវបានរៀបចំ ដើម្បីរៀនពីបទពិសោធន៍ផ្សេងៗគ្នា ផងដែរ

### (IV) ***ការអប់រំសាធារណៈ***

វាចាំបាច់ត្រូវបង្កើតចន្លោះមិនផ្លូវការ ដើម្បីធ្វើអន្តរកម្មជាមួយប្រជាពលរដ្ឋ ។ ដំណើរការនៃការអប់រំសាធារណៈ និង ការកសាងការយល់ដឹង គឺបានផ្តួចផ្តើមឡើងតាមរយៈការរៀបចំ និងបែងចែកលិខិតរិះគន់ សៀវភៅតូចដ៏មានប្រជាប្រិយ ការប្រឡងប្រណាំងគំនូរ ការសម្តែងតាមដងផ្លូវ ការបង្ហាញតាមតុក្កតា និងតាមរយៈសម្ភារអប់រំដទៃទៀត ។ ព្រឹត្តិបត្រប្រចាំខែអាចបោះពុម្ពផ្សាយនៅតាមក្រុងនីមួយៗ ។ នេះអាចជា ព្រឹត្តិបត្រព័ត៌មានថ្នាក់ក្រុង សម្រាប់ប្រជាពលរដ្ឋ ឱ្យស្គាល់ពីគ្រោងការណ៍របស់រដ្ឋាភិបាល គោលនយោបាយ ផែនការក្រុង កញ្ចប់ថវិកា និង ដើម្បីលើកជាតម្រូវការ ។ ផ្នែកមួយនៃឯកសារព្រឹត្តិបត្រ រៀបរាប់នូវអ្វីដែលបានកើតឡើងក្នុងក្រុង នៅពេលដែលត្រូវបានរាយការណ៍ដោយប្រជាពលរដ្ឋ ហើយនៅក្នុងផ្នែកមួយផ្សេងទៀតអាជ្ញាធរក្រុង ផ្តល់ព័ត៌មានទាក់ទិនទៅនឹងសកម្មភាពអភិវឌ្ឍន៍ដែលបានធ្វើផែនការសម្រាប់ក្រុង ។ អត្ថបទខ្លះក្តោបការដាក់បញ្ចូលគោលនយោបាយរដ្ឋ/គោលនយោបាយថ្នាក់កណ្តាល ដំណោះស្រាយ របស់រដ្ឋាភិបាលដែលទាក់ទងនឹងអភិបាលកិច្ចក្រុង កំណត់ត្រាស្តីពីការសិក្សាថ្នាក់ជាតិ និងអន្តរជាតិ លើបញ្ហារបស់រដ្ឋាភិបាល ករណីសិក្សានៃការអនុវត្តបានល្អបំផុតអំពីភាពជាដៃគូរវាងផ្នែកឯកជន និង ផ្នែកសាធារណៈ គំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ ការទទួលខុសត្រូវរបស់អាជ្ញាធរក្រុង ការកែប្រែ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាមូលដ្ឋាន និង ទស្សនរបស់ ប្រជាពលរដ្ឋទៅលើអភិបាលកិច្ច ជាដើម ។ល។

## (៤) ការកសាងសមត្ថភាពរបស់អ្នកដឹកនាំប្រជាពលរដ្ឋ

វាជាការសំខាន់ណាស់ ដើម្បីពង្រឹងសមត្ថភាពរបស់អ្នកដឹកនាំប្រជាពលរដ្ឋ ដោយសារពួកគេដើរតួនាទីយ៉ាងសកម្ម ក្នុងការប្រកាន់យកការទទួលខុសត្រូវ លើផ្នែកអភិបាលកិច្ចមូលដ្ឋាន និងក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ផ្នែកអ្នកដែលគេមិនអើពើក្នុងសង្គម ។ ពេលប្រជាពលរដ្ឋត្រូវគេជូនដំណឹង ដែលត្រូវបានគេឱ្យរៀបចំ និងឱ្យមានសកម្មភាពសកម្មនោះ វាអាចធ្វើឱ្យមានឥទ្ធិពល ទៅលើគុណភាពនៃអភិបាលកិច្ច ។ ពួកគេគួរស្គាល់ពីសិទ្ធិ និង ការទទួលខុសត្រូវ ។ នៅក្នុងបរិបទនេះ ការកសាងសមត្ថភាពនៃមេដឹកនាំរបស់ប្រជាពលរដ្ឋអាចធ្វើឡើង តាមរយៈកម្មវិធីបណ្តុះបណ្តាល ។ មេដឹកនាំប្រជាពលរដ្ឋ គឺជាមេដឹកនាំពិត។ ហើយមិនមែនជាតំណាងដែលជ្រើសរើសរបស់សង្កាត់ទេ ។ ពួកគេជាអ្នកស្ម័គ្រចិត្តសង្កាត់ដែលធ្វើការបន្ថែម ដើម្បីជួយដល់ប្រជាពលរដ្ឋងាយរងគ្រោះ ។ ពួកគេគាំទ្រដល់បញ្ហារបស់ក្រុមដែលខូចខាតប្រយោជន៍ និងដាក់ជាសម្ពាធដល់អាជ្ញាធរក្រុង ។ មេដឹកនាំប្រជាពលរដ្ឋទាំងនោះ ចាប់ធ្វើជាដំបូងទៅក្នុងការត្រួតពិនិត្យ ទៅលើសេវាមូលដ្ឋានរួមជាមួយតំណាងសង្កាត់ ដែលបានជ្រើសរើស ដើម្បីចាប់ពួកគេឱ្យទទួលខុសត្រូវ និងភ្ជាប់ជាមួយមណ្ឌលគាំទ្រប្រជាពលរដ្ឋ សម្រាប់ទទួលព័ត៌មានចុងក្រោយបំផុត ក្នុងការចែករំលែកដល់ថ្នាក់សង្កាត់ ក៏ដូចជាផ្តល់ព័ត៌មានត្រឡប់ ទៅអាជ្ញាធរក្រុងវិញផងដែរ ។

## សេចក្តីសន្និដ្ឋាន

ការចូលរួមដោយខ្ជាប់ខ្ជួនរបស់ពលរដ្ឋ អាចជួយដល់អាជ្ញាធរមូលដ្ឋាន ឱ្យរកឃើញនូវការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ចំណាយតិច ហើយចំ។ទៅនឹងបញ្ហារបស់ក្រុង ។ ដើម្បីដោះស្រាយ នូវបញ្ហាទាំងអស់នេះ វាជាការសំខាន់សម្រាប់អាជ្ញាធរគ្រប់គ្រងមូលដ្ឋាន ដើម្បីចូលរួមឱ្យបានខ្ជាប់ខ្ជួន ជាមួយនឹងប្រជាពលរដ្ឋ ។ ទោះជាយ៉ាងណា ក៏នាពេលបច្ចុប្បន្ន វេទិកាដ៏សមរម្យគឺធ្វើសម្រាប់ទាំងចំណុចអវត្តមាន ឬ ទាំងចំណុចអសមត្ថភាព ក្នុងការរចនាប្លង់ និង រចនាសម្ព័ន្ធ ។ ទីពីរ វត្តមាននៃភ្នាក់ងារប្រជាពលរដ្ឋ នៅតាមវិស័យនានានៃទីក្រុង មានកម្រិតនៅឡើយ ហើយភាគច្រើនស្ថិតនៅក្នុងវិស័យជាក់លាក់មួយចំនួនតែប៉ុណ្ណោះ ។ ជាឧទាហរណ៍ ខណៈដែលភ្នាក់ងារជាច្រើន កំពុងធ្វើការផ្តល់សេវា ទៅលើផ្នែកសុខភាព និង ការផ្តល់សេវាអប់រំកម្រិតបឋមសិក្សា ភ្នាក់ងារតិចតួចណាស់ បាននឹងកំពុងចូលរួមដោយខ្ជាប់ខ្ជួន ទៅនឹងបញ្ហាដែលទាក់ទងជាមួយការធ្វើផែនការ និង អភិបាលកិច្ចទីក្រុង ។ ទីបី អវត្តមាននៃគម្លាត និងខ្វាតរង្វាស់ សម្រាប់សកម្មភាព

ដោយផ្ទាល់របស់ប្រជាពលរដ្ឋ វត្តមាននៃភ្នាក់ងាររបស់ប្រជាពលរដ្ឋ ក្លាយជាមានសារៈសំខាន់ ។ បើទោះជាយ៉ាងណាក៏ដោយ ការជាប់ទាក់ទងជាមួយភ្នាក់ងារប្រជាពលរដ្ឋ បានជួយទ្រទ្រង់ ក្នុងការសម្របសម្រួលដល់សកម្មភាព នៃការបង្កើតស្ថាប័នប្រជាពលរដ្ឋ ។ ការជាប់ទាក់ទងជាបន្តបន្ទាប់ ដូចនេះ អាចធានាបាននូវប្រសិទ្ធភាព និងសកម្មភាពផ្តល់អំណាចដល់ប្រជាពលរដ្ឋ ។ ហើយជាចុងក្រោយ ប្រសិនបើ គម្លាតដែលទើបបង្កើតថ្មីៗមានគុណតម្លៃ ដោយផ្អែកលើមូលដ្ឋានប្រជាធិបតេយ្យ គ្រប់ផ្នែកទាំងអស់របស់ប្រជាពលរដ្ឋ ដោយរួមទាំងស្ត្រីនឹងមានអារម្មណ៍យល់ដឹង ពីការជាប់ទាក់ទង និងភាពជាម្ចាស់ ។ ការចូលរួមរបស់ជនក្រីក្រ គឺមិនមែនជាឧបសគ្គតាមរយៈភាពលំបាកផ្នែកសេដ្ឋកិច្ចរបស់ពួកគេឡើយ តែតាមរយៈទំនាក់ទំនងនៃអំណាច ដែលមិនបានដាក់បញ្ចូលទៅវិញនោះទេ ។ ដូច្នេះ ដំណើរការនៃការផ្តល់អំណាចណាមួយ គឺជាលក្ខណៈនយោបាយ និង គួរតែមានទិដ្ឋភាពដូចនេះ។ ការចូលរួមដោយខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ ត្រូវបានមើលឃើញថា ជាកិច្ចដំណើរការមួយនៃការកែតម្រូវទៅលើគម្លាតរបស់ប្រជាពលរដ្ឋ ដើម្បីមានឥទ្ធិពល និង បង្កើតចេញជារូបរាងនៃការអភិវឌ្ឍទាំងមូល ។

## Reference


1. Malik Khalid and Wagle Swarnim, Civic Engagement and Development: Introducing the Issues, UNDP, 2002
2. UNDP, October 2002, UNDP Practice Area: Democratic Governance Synthesis of Lesson Learned, Civic Engagement, Essentials, No 8
3. Logolink, Citizens Participation in Urban Local Bodies, Policy Implications for Urban Development, Policy Paper Urban Development, as part of the Research project on ReCite
4. Apikul Christine, Improving Government, Citizen Intervention, eGov Balkan Bulgaria, 2006
5. UNDP, The Key to Increasing Transparency in e- Government Development: Public Feed Back Mechanism, APDIP e note, 3/2005
6. William Reuben, The Role of Civic Engagement and Social Accountability in the Governance Equation, Social Development Note, No. 74, March 2003
7. Participation and Civic Engagement, Citizen Report Card Survey: A Note on the Concept and Methodology, Social Development Note, Note, 91, February 2004.
8. Kumar Yogesh, Lesson Learnt from Urban Governance Initiative, UNNATI, 2006
9. UNNATI, Citizen Support Cell: A Note, 2001
10. Cornwall Andrea and Gaventa John, Bridging the Gap: Citizenship, Participation and Accountability, PLA notes February, 2001.
11. Swiss Agency for Development and Co operation, Participatory Budgets: A Tool for a Participatory Democracy, Urban News, February, 2003
12. Kadoyama Margaret, Practicing Civic Engagement: Major Challenges and Innovative Approaches, www.margaretkadoyama.com
13. UNDP, Human Development Report, OUP, 1993
14. Edgerton et al, 2000.